# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation
លេខ: ៣៦៣ MISTI / ២០២០

## ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មាធិការវាយតម្លៃទទួលស្គាល់ជំនាញមាត្រាសាស្ត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រ
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញប្រកាសអន្តរក្រសួងលេខ៥៥៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់ ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញប្រកាសលេខ១៤៤ MISTI/២០២០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

### ប្រការ១ .-

ប្រកាសនេះមានគោលដៅកំណត់អំពីយន្តការគ្រប់គ្រង អនុវត្តការវាយតម្លៃលើសមត្ថភាពបុគ្គល និងការផ្តល់វិញ្ញាបនបត្រទទួលស្គាល់ជំនាញមាត្រាសាស្ត្រ នៅព្រះរាជាណាចក្រកម្ពុជា។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)
ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: misti.smcabinet@gmail.com

**ប្រការ២.-**

ប្រកាសនេះមានគោលបំណងដូចខាងក្រោម៖

- ធ្វើឱ្យមានជំនឿ និងទំនុកចិត្តលើវិស័យមាត្រាសាស្ត្រ
- អនុវត្តជំនាញមាត្រាសាស្ត្រប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ
- ជំរុញការយល់ដឹងជំនាញមាត្រាសាស្ត្រ និងផ្សព្វផ្សាយអំពីលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យមាត្រាសាស្ត្រ
- កំណត់អត្តសញ្ញាណ ដើម្បីជំរុញការអភិវឌ្ឍធនធានមនុស្សលើវិស័យជំនាញមាត្រាសាស្ត្រ
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជនដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តជាអាទិ៍ ចំពោះបុគ្គលដែលប្រកបអាជីវកម្ម និងសេវាកម្ម ក្នុងសកម្មភាពជំទើ្យង ជួសជុល និងផលិតឧបករណ៍មាត្រាសាស្ត្រ ត្រូវមានវិញ្ញាបនបត្រទទួលស្គាល់ជំនាញមាត្រាសាស្ត្រ។

**ប្រការ៤.-**

វាក្យស័ព្ទសំខាន់ៗប្រើក្នុងប្រកាសនេះមានដូចតទៅ៖

**មាត្រាសាស្ត្រ** សំដៅដល់ វិទ្យាសាស្ត្រ និងការគ្រប់គ្រងទម្ងន់ និងរង្វាស់រង្វាល់។

**ឧបករណ៍មាត្រាសាស្ត្រ** សំដៅដល់ឧបករណ៍ទម្ងន់ និងរង្វាស់រង្វាល់ដែលបម្រើឱ្យវិស័យមាត្រាសាស្ត្រ។

**ឧបករណ៍វាស់វាល់** សំដៅដល់ឧបករណ៍មាត្រាសាស្ត្រសម្រាប់ប្រើប្រាស់រកបរិមាណនៃប្រព័ន្ធឯកតា ចំណុះវត្ថុរាវ ប្រវែង សម្ពាធ សំទ្បេង ពន្លឺ ថាមពល ។ល។

**បុគ្គល** សំដៅដល់ រូបវន្តបុគ្គល ដែលដាក់ពាក្យស្នើសុំវិញ្ញាបនបត្រទទួលស្គាល់ជំនាញមាត្រាសាស្ត្រ។

**វិញ្ញាបនបត្រ** សំដៅដល់ វិញ្ញាបនបត្រទទួលស្គាល់ជំនាញមាត្រាសាស្ត្រ ដែលបានចុះបញ្ជិកាជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការវាយតម្លៃទទួលស្គាល់ជំនាញមាត្រាសាស្ត្រសម្រាប់យកទៅប្រើប្រាស់តាមផ្លូវច្បាប់។

**គណៈកម្មាធិការ** សំដៅដល់គណៈកម្មាធិការវាយតម្លៃទទួលស្គាល់ជំនាញមាត្រាសាស្ត្រ ដែលមានចែងក្នុងប្រកាសនេះ។

**ប្រការ៥.-**

ត្រូវបានបង្កើតគណៈកម្មាធិការវាយតម្លៃទទួលស្គាល់ជំនាញមាត្រាសាស្ត្រនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | រដ្ឋលេខាធិការទទួលបន្ទុក | ប្រធាន |
| ២- | អនុរដ្ឋលេខាធិការទទួលបន្ទុក | អនុប្រធាន |
| ៣- | ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- | អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | សមាជិក |
| ៥- | ប្រធាននាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ ឬតំណាង | សមាជិក |
| ៦- | ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ ឬតំណាង | សមាជិក |
| ៧- | ប្រធាននាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម ឬតំណាង | សមាជិក |
| ៨- | ប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ ឬតំណាង | សមាជិក |


ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: misti.smcabinet@gmail.com

គណៈកម្មាធិការនេះ មាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ ជាសេនាធិការ ដើម្បីសម្របសម្រួល និងអនុវត្តភារកិច្ច ស្របតាមបញ្ញត្តិនៃប្រកាសនេះ។

សមាសភាពខាងលើ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការ។ ក្រៅពីសមាជិកខាងលើ ប្រធានគណៈកម្មាធិការ អាចស្នើសុំបន្ថែមសមាជិកតាមការចាំបាច់។

ការតែងតាំងសមាសភាពឈ្មោះមន្ត្រីរាជការខាងលើ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៦ ..**

បែបបទនៃការស្នើសុំវិញ្ញាបនបត្រ ត្រូវដាក់ពាក្យស្នើសុំ នៅការិយាល័យច្រកចេញ-ចូលតែមួយ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រៀងរាល់ថ្ងៃម៉ោងធ្វើការ។

សំណុំឯកសារតម្រូវភ្ជាប់មកជាមួយមានដូចខាងក្រោម៖

| | |
|---|---|
| ១. ពាក្យស្នើសុំវិញ្ញាបនបត្រ | ចំនួន ០១ ច្បាប់ |
| ២. ប្រវត្តិរូបសង្ខេប (មានបិទរូបថត ទំហំ ៤×៦ ) | ចំនួន ០១ ច្បាប់ |
| ៣. វិញ្ញាបនបត្របណ្តុះបណ្តាល ឬឯកសារមានតម្លៃស្មើ | ចំនួន ០១ ច្បាប់ |
| ៤. អត្តសញ្ញាណបណ្ណ ឬឯកសារមានតម្លៃស្មើ | ចំនួន ០១ ច្បាប់ |
| ៥. រូបថត (ថតចំពីមុខ) ទំហំ ៤×៦ | ចំនួន ០២ សន្លឹក។ |

**ប្រការ៧ ..**

បន្ទាប់ពីបានពិនិត្យឃើញថា ការបំពេញបែបបទស្នើសុំ និងឯកសារតម្រូវ តាមប្រការ៦ នៃប្រកាសនេះត្រឹមត្រូវ និងគ្រប់គ្រាន់ នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ ត្រូវរៀបចំសម្របសម្រួលឯកសារជូនគណៈកម្មាធិការ ដើម្បី ពិនិត្យ និងផ្តល់អនុសាសន៍ដល់នាយកដ្ឋានជំនាញរៀបចំវាយតម្លៃជាបឋម តាមរយៈការធ្វើតេស្តអនុវត្តជាក់ស្តែង ឬ/និងសម្ភាសន៍ផ្ទាល់មាត់ និងត្រូវផ្តល់លទ្ធផលនៃការវាយតម្លៃយ៉ាងយូរ ០៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

ក្រោយពីបានលទ្ធផលការវាយតម្លៃជាបឋម គណៈកម្មាធិការ ត្រូវធ្វើការពិនិត្យវាយតម្លៃទទួលស្គាល់ជំនាញមាត្រាសាស្ត្រ និងផ្តល់វិញ្ញាបនបត្រ ពិនិត្យសម្រេចដោយប្រធានគណៈកម្មាធិការ ជូនក្នុងរយៈពេល ២០(ម្ភៃ)ថ្ងៃ យ៉ាងយូរនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលបែបបទស្នើសុំ និងឯកសារតម្រូវបានត្រឹមត្រូវ។

គណៈកម្មាធិការនេះ មានសិទ្ធិប្រើត្រាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់បោះលើវិញ្ញាបនបត្រ។ វិញ្ញាបនបត្រនេះ មានសុពលភាពជាអចិន្ត្រៃយ៍។

**ប្រការ៨ ..**

បុគ្គលដែលបានកាន់វិញ្ញាបនបត្រនេះ៖

- ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈ និងត្រូវតែគោរពពាល់បទប្បញ្ញត្តិ ដូចមានចែងក្នុងច្បាប់ ស្តីពីមាត្រាសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យមាត្រាសាស្ត្រ
- ក្នុងករណី មិនបានបម្រើការងារជំនាញមាត្រាសាស្ត្រដែលបានបញ្ជាក់ក្នុងរយៈពេល ៣(បី)ឆ្នាំ ត្រូវមកដាក់ពាក្យស្នើសុំបញ្ជាក់ទទួលស្គាល់ជំនាញមាត្រាសាស្ត្រជាថ្មី។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ឧទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ៩ ._**

ប្រកាសលេខ ២២៦ MIH/២០១៩ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការវាយតម្លៃទទួលស្គាល់ជំនាញមាត្រាសាស្ត្រ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ ._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ និងគ្រប់អង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៧កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០២០

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

**កន្លែងទទួល៖**

- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១០
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ៖ (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល៖ misti.smcabinet@gmail.com